**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

តុលាការកំពូល
សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ០៥
ចុះថ្ងៃទី០៦-០១-១៩៩៨
សាលដីកាលេខ៖៣៤
ចុះថ្ងៃទី៣០-១២-១៩៩៨

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម... ប្រធាន
២- លោក... ចៅក្រមរបាយការណ៍
៣- លោក... ចៅក្រម
៤- លោក... ចៅក្រម
៥. លោក... ចៅក្រម

ក្រឡាបញ្ជីលោក...

តំណាងមហាអយ្យការ លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌ លេខ៥ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល។

ពីបទៈប៉ុនប៉ងធ្វើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦-៨-៩៦ បទ

ល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាម បញ្ញតិមាត្រា៣១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១-ជនជាប់ចោទឈ្មោះ **សផ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរកើតនៅភូមិទួលទំពូង ខណ្ឌលេខ៧ ក្រុងភ្នំពេញ របររកស៊ីនគរបាល ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃ ភូមិខ្ពបវែង ឃុំកំពង់សំណាញ់ ស្រុកតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន៥នាក់។ ចាប់ខ្លួនថ្ងៃទី១៧-១០-១៩៩៦។

មានមេធាវី លោក...ការពារឱ្យជនជាប់ចោទ។

២-ជនជាប់ចោទឈ្មោះ **អចថ (អិត)** ភេទប្រុស អាយុ២៩ឆ្នាំ ទីកន្លែងកំណើត ភូមិព្រៃរបង ឃុំស្រែបែក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ របររកស៊ីនគរបាលការពារស្នងការនគរបាល ខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃ ភូមិព្រែកឬស្សី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន៣នាក់។ ចាប់ខ្លួនថ្ងៃទី១៧-១០-១៩៩៦ (ស្លាប់)។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សស** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ របររកស៊ីនគរបាលខេត្ត ទីលំនៅសព្វថ្ងៃភូមិ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល។

មេធាវី គ្មាន

-តាមបណ្តឹងសាទុក្ខលេខ ៣៥៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ **សផ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

- តាមរបាយការណ៍បូកសរុបរបស់ស្នងការដ្ឋាននគរបាលខេត្តកណ្តាល ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ថា៖ នៅរដូវចូលឆ្នាំខ្មែរ ឆ្នាំ១៩៩៦ ជនរង

គ្រោះឈ្មោះ **លវណ** មានទំនាស់យ៉ាងខ្លាំងជាមួយគ្រួសារជនល្មើស ឈ្មោះ**អចថ** អំពីបញ្ហាលក់ដូរ។ ក្រោយពេលមានទំនាស់គ្នាមក គ្រួសារទាំងពីរចេះតែបោះពាក្យបញ្ចិតបញ្ចៀងគ្នាទៅវិញទៅមក។ លុះដល់ថ្ងៃទី១៥-៨-៩៦ ឈ្មោះ **អចថ** និង ឈ្មោះ **ផល្ល** បានបាយជុំគ្នានៅផ្ទះម្ដាយមីងរបស់ឈ្មោះ **អចថ**(បាយពេលយប់)។ អ្នកទាំងពីរ បានពិភាក្សាគ្នា អំពីរឿង ដាក់គ្រាប់បែកសម្លាប់ឈ្មោះ **សស** និងគ្រួសារ ដោយឈ្មោះ **អចថ** ជាអ្នកផ្ដើមគំនិត ចំណែកឈ្មោះផល្ល ជាអ្នកដៃដល់ក្នុងការដាក់គ្រាប់បែកដោយឈ្មោះ **អចថ** បាននិយាយធានាជួយផ្ដល់លុយកាក់និងកន្លែងរកស៊ីដល់គ្រួសាររបស់ឈ្មោះ**ផល្ល** នៅពេលណាធ្វើការនោះសម្រេច។ ការពិភាក្សាគ្នា២ថ្ងៃទើបឈ្មោះ **ផល្ល** យល់ព្រម។ នៅថ្ងៃទី១៩-៨-៩៦ ឈ្មោះ **អចថ** បានជួបឈ្មោះ**ផល្ល** ពិភាក្សាគ្នា និងបានប្រាប់ចំណុចកន្លែងបង្កប់គ្រាប់បែក។ បន្ទាប់មកថ្ងៃទី២៥.៨.៩៦ វេលាម៉ោង១, ១៥នាទីយប់ឈ្មោះ**ផល្ល** បានយកគ្រាប់ដែលឈ្មោះ **អចថ** ប្រគល់ឱ្យទៅចងបង្កប់នៅទ្វារផ្ទះរបស់ឈ្មោះ **សស** តាមការកំណត់របស់ឈ្មោះ **អចថ**។ លុះដល់ថ្ងៃទី២៦-៨-៩៦ វេលាម៉ោង៥,៥០នាទី ឈ្មោះ **លវណ** ប្រពន្ធរបស់ឈ្មោះ **សស** ចេញមកបើកទ្វារផ្ទះពេលនោះគ្រាប់បែកដែលឈ្មោះ **ផល្ល** ចងបង្កប់ទុកក៏ផ្ទុះតែម្ដង បណ្ដាលឱ្យត្រូវរបួសឈ្មោះ **លវណ** និងកូនប្រុសឈ្មោះ **សជរ** ជាទម្ងន់។

-តាមពាក្យបណ្ដឹងចុះថ្ងៃទី២៦-៨-៩៦ របស់ឈ្មោះ **សស** ប្ដឹង ពីជនមិនស្គាល់មុខដែលយកគ្រាប់បែកមកបង្កប់នៅផ្ទះរបស់ខ្លួន ដើម្បីប៉ុនប៉ងសម្លាប់ខ្លួនព្រមទាំងគ្រួសារ ដោយហេតុថា កាលពីថ្ងៃទី២៦-៨-១៩៩៦ ម៉ោង៥,៥០នាទីទៀបភ្លឺប្រពន្ធខ្លួន បានចុះមកបើកទ្វារផ្ទះឯចំណែកខ្លួនក៏ងើបឡើងអង្គុយបម្រុងចុះស្រាប់តែគ្រាប់បែកមួយគ្រាប់បានផ្ទុះឡើង បណ្ដាលឱ្យរងរបួសជាទម្ងន់ និងខូចខាតសម្ភារមួយចំនួនដូចជា៖

១-ទូរសស្សន៍ ០១ គ្រឿង ធុន ១៤ ពណ៌

២-ម៉ាញ៉េ ០១ គ្រឿង ធុន ៤០ w

៣-អាគុប ០១ គ្រឿងបាត់ធុនP2 AT

៤-សម្ភារមួយចំនួនទៀត។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តកណ្ដាលបានធ្វើសេចក្ដីសន្និដ្ឋានថាៈ ក្រោយពីបានស្ដាប់ចម្លើយដោះសារបស់ជនជាប់ចោទ ជនរងគ្រោះ សាក្សី និងបានពិនិត្យចម្លើយសារភាពរបស់ជនជាប់ចោទ នៅចៅក្រមស៊ើបអង្កេត ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំងពីរនេះហើយ តំណាងអយ្យការសម្រេចតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ១៦៥ដ.ក- សព៩៧ ចុះថ្ងៃទី១៣-០២-៩៧ទុកជាបានការពេញលេញ និងសំណូមពរសុំឱ្យលោកចៅក្រមពិនិត្យពិចារណានិងសម្រេចទៅតាមច្បាប់ចុះ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៧(រ) ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្ដាល ដែលបានសម្រេចដូចតទៅៈ

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ **អចថ** ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ **សផ** ភេទប្រុស អាយុ៣៧ឆ្នាំ ដាក់ពន្ធនាគារ ក្នុងម្នាក់ៗកំណត់៧ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី១៧-១០-៩៦ ពីបទៈឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រពើហា ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦-៨-៩៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣១,៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-៩-៩២។

២-វត្ថុតាងមានក្រវិលគ្រាប់បែក អំបែង៥ ដុំនិងខ្សែពណ៌ត្លួយចេក១ត្រូវបំផ្លាញចោល។

៣-បង្គាប់ឱ្យជនជាប់ចោទ រួមគ្នាសងសំណងការខូចខាតសម្ភារថ្លៃព្យាបាលនិងជំងឺចិត្តសរុបចំនួន២.០០០ដុល្លាអាមេរិក(ពីរពាន់ដុល្លាអាមេរិក)សុំលើសពីនោះលើកចោល។

-ករណីរឹងទទឹងពុំព្រមសងប្រាក់ធនទណ្ឌតាមការកំណត់ខាងលើ ត្រូវដាក់គុកបង្ខំ លើរូបកាយតាមបញ្ញត្តិមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ១៨ក្រចុះថ្ងៃទី៨-២-៩២។

-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងជនរងគ្រោះ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែដោយគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៦ ចុះថ្ងៃទី១៨ខែមីនាឆ្នាំ១៩៩៧របស់ឈ្មោះ **អចថ** និងឈ្មោះ **សផ** ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ០៧ (វ) ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៧ របស់តុលាការខេត្តកណ្តាលលើសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨-៣-៩៧ របស់ជនជាប់ចោទទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-ចាត់អង្កេតតាមការអះអាងរបស់ជនជាប់ចោទថាមានការបង្ខិតបង្ខំនិងគំរាមឱ្យឆ្លើយមុនពេលឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត។

៣-កែប្រែត្រង់ចំណុចទី១ នៃសេចក្តីសម្រេចរបស់សាលក្រម ខាងលើដោយ

-កែប្រែបទចោទលើឈ្មោះ **អចថ** ពីបទៈឃាតកម្មគិតទុកជាមុនមកជាបទសមគំនិតធ្វើឃាតកម្មគិតទុកជាមុនតាមមាត្រា៦៩,៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-កែប្រែបទចោទលើឈ្មោះ **សផ** ពីបទៈឃាតកម្មគិតទុកជាមុនមកជាបទប៉ុនប៉ងធ្វើឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា៣១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្រៅពីនេះតម្កល់ទុកជាបានការ បើសិនគ្មានភស្តុតាងផ្ទុយ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ**សផ** ចុះថ្ងៃទី១៨-៣-១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ **អចថ** ចុះថ្ងៃទី១៨.៣-១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

៣-ចំណុចទី១នៃសាលក្រមលេខ០៧ ចុះថ្ងៃទី៦-៣-១៩៩៧ របស់តុលាការខេត្តកណ្តាល ត្រង់ឃ្លាថាឈ្មោះ **អចថ** ភេទប្រុស អាយុ២៩ឆ្នាំ និងចំណុចទី៣ ត្រង់ពាក្យថា(រួមគ្នា) ត្រូវបដិសេធចោលនិងចំណុចទី១ នៃសាលក្រមខាងលើត្រង់ពាក្យថា ក្នុងម្នាក់ៗកំណត់៧ឆ្នាំ ត្រូវតែប្រែថាកំណត់៦ឆ្នាំវិញ។ ក្រៅពីនេះតម្កល់ទុកជាបានការដដែល។

៤-ឱ្យឈ្មោះ **អចថ** រួចផុតពីបទចោទពីបទឃាតកម្មគិតទុកជាមុនមានថែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បង្គាប់ឱ្យដោះលែងឈ្មោះ **អចថ** ភ្លាមបើឈ្មោះនេះមិនត្រូវបានជាប់ឃុំឃាំងពីបទចោទផ្សេងទៀតទេ យោងតាមបញ្ញត្តិមាត្រា១៩៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៩-សាលដីកានេះ ប្រកាសជាសាធារណៈ ចំពោះមុខអ្នកការពារឱ្យជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១០-៩-១៩៩៧ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ជនជាប់ចោទឈ្មោះ **សួន ផល្លា** ដែលប្តឹងតវ៉ាពី សាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៨ របស់ឈ្មោះ **សផ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី២០ខែឧសភាឆ្នាំ១៩៩៨ របស់ឈ្មោះ **សស** (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់អំណានសាវតាជាតិ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សស** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

១-បណ្តឹងសាទុក្ខរបស់ឈ្មោះ **សផ** ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមកពិនិត្យពិចារណា។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០-៩-៩៧ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់។

-បានស្តាប់អំណានសារណារបស់ឈ្មោះ **សស** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះ។

-បានស្តាប់ចម្លើយដោះសារបស់ជនជាប់ចោទឈ្មោះ **សផ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នាពេលជំនុំជម្រះថា៖ ខ្ញុំបាទអត់ដឹងអ្វីទាំងអស់ អត់ចេះប្រើគ្រាប់ទេ ហើយក៏មិនបានទៅលេងផ្ទះមីងនៅតាខ្មៅដែរ កាលនៅនគរបាលគេបង្ខំឱ្យខ្ញុំនិងឈ្មោះ **អចថ** ឆ្លើយសារភាព ចាប់ខ្ញុំបាទនៅកណ្តាលផ្លូវតែម្តង គឺខ្ញុំបាទពុំបានដឹងទេ សូមតុលាការជួយរកយុត្តិធម៌។

-បានស្តាប់សេចក្តីសន្និដ្ឋានការពារ របស់លោក...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **សផ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ គ្មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាកូនក្តីខ្ញុំ បានប្រព្រឹត្តអំពើធ្វើមនុស្សឃាតគិតទុកជាមុននោះទេ ព្រោះថាតាម ពាក្យបណ្តឹងរបស់ឈ្មោះ **សស** ប្តឹងពីជនមិនស្គាល់មុខ ហើយផ្អែកតាមចម្លើយបង្ខិតបង្ខំ ជនល្មើសតែមួយនៅនគរបាល មិនអាចយកជាការបានឡើយ។ ម្យ៉ាងទៀតការចាប់ខ្លួនកូនក្តីខ្ញុំបាទ គ្មានដីកាចាប់ខ្លួនពីតុលាការទេ។ ដូច្នេះសូមតុលាការដោះលែងឱ្យមានសេរីភាព និងសូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ហើយសូមទាមទារទ្រព្យសម្បត្តិដែលតុលាការថ្នាក់ក្រោមរឹបអូសប្រគល់ជូនគ្រួសារកូនក្តីខ្ញុំបាទវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋាន បន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ សូមរក្សាសេចក្តីសន្និដ្ឋាននៅដដែល

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់ជនជាប់ចោទ សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣៥៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៧ របស់ឈ្មោះ **សផ** ធ្វើឡើងក្នុងកំណត់ច្បាប់។ តុលាការកំពូលអាចលើក រឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភា ពរបស់សាលាជម្រះក្តី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យឈ្មោះ **អចថ** រួចផុត ពីបទចោទ និងផ្តន្ទាទោសឈ្មោះ **សផ** ដោយអាងហេតុថាឈ្មោះ **អចថ**គ្មានពិរុទ្ធ ភាព រីឯឈ្មោះ **សផ** ពិតជាមានពិរុទ្ធភាពពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយ ចេតនានោះ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាភស្តុតាងដើម្បីចោទប្រកាន់លើ ជនទាំងពីរ គឺសំអាងទៅលើចម្លើយសារភាពរបស់សាម៉ីខ្លួនតែប៉ុណ្ណោះ ដូចមាន នៅក្នុងកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩៦ ឈ្មោះ **អចថ** បានឆ្លើយ សារភាពថាខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ**សផ** បានប្រាប់ឱ្យឈ្មោះ **សផ** ដាក់បង្កៃគ្រាប់បែកនៅមុខផ្ទះឈ្មោះ **សស** ដូច្នេះអ្នកទាំងពីរត្រូវមានពិរុទ្ធ ភាពដូចគ្នាបើគ្មានពិរុទ្ធក៏ត្រូវដូចគ្នាដែរ។

-យល់ឃើញថាជនជាប់ចោទ បានប្តឹងសុំបដិសេធចម្លើយសារភាពរបស់ ខ្លួននៅចំពោះមុខនគរបាលក៏ដូចនៅចំពោះមុខចៅក្រមស៊ើបអង្កេត ដោយអាង ហេតុថាៈចម្លើយទាំងនោះបានមកដោយការបង្ខិតបង្ខំ ប៉ុន្តែសាលាឧទ្ធរណ៍មាន ការខ្វះខាត ដោយពុំបានពិចារណានិងសម្រេចអំពីពាក្យសុំនោះទេ។

-យល់ឃើញថាទាំងសាលាឧទ្ធរណ៍ ទាំងតុលាការខេត្តកណ្តាលមានការ ខ្វះខាត ដោយពុំបានសម្រេចអំពីសម្ភារប្រើប្រាស់ដូចជាកង់មីតី១គ្រឿងពណ៌ ក្រហម នាឡិកាដៃមីដូ ១គ្រឿង អាគុយ៣កា ១គ្រឿងប្រើបាន ដែលពុំមែនជា វត្ថុតាងយកទៅប្រព្រឹត្តបទល្មើសឡើយ។

-យល់ឃើញថា សាលាឧទ្ធរណ៍មានការខុសឆ្គងដូចការលើកឡើងរបស់មេធាវីជនជាប់ចោទនាសវនាការនេះ ថាសាលាឧទ្ធរណ៍សម្រេចសេចក្តីក្នុងរឿងឧក្រិដ្ឋដោយពុំបានចាត់តាំងមេធាវី ឱ្យជនជាប់ចោទឈ្មោះ **សផ** តាមមាត្រា១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-យល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះកំបាំងមុខដើមបណឹងរដ្ឋប្បវេណីប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី១០ខែកញ្ញា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ។

១-ទទួលបណ្តឹងសាទុក្ខលេខ៣៥៩ចុះថ្ងៃទី២៣ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ **សផ** ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១៨៥ចុះថ្ងៃទី១០ខែកញ្ញាឆ្នាំ ១៩៩៧របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ០៥ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨។